# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១ សសរ

## សេចក្ដីសម្រេច

## ស្ដីពី

## ការចាត់តាំងសមាសភាពក្រុមពិភាក្សា និងក្រុមបូកសរុប ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី ចម្រុះ កម្ពុជា ថៃ នាថ្ងៃទី៣១ ខែឧសភា និង ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៣

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ចាត់តាំងសមាសភាព នៃក្រុមពិភាក្សា និងក្រុមបូកសរុប ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះ កម្ពុជា ថៃ ដែលមាន៥ក្រុម និងក្រុមបូកសរុបមួយក្រុម ដូចខាងក្រោម :

**១-ក្រុមពិភាក្សាទី១ : អំពីបញ្ហាសន្តិសុខ**

១- ឯកឧត្តម ហោ ណាំហុង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាន

២- ឯកឧត្តម ទៀ បាញ់ ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

៣-ឯកឧត្តម យូ ហុកគ្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សមាជិក

៤- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

៥- ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦-ឯកឧត្តម ឡាវ ស៊ីថុង រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ សមាជិក

៧- ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សមាជិក

៨- ឯកឧត្តម នាយឧត្តមសេនីយ៍ហុក ឡុងឌី អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក

៩- ឯកឧត្តម ហោង វង្សប៊ុនឆាត ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល សមាជិក

១០- ឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

១១- ឯកឧត្តម វ៉ា គឹមហុង ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

១២- ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

-**លេខាររបស់ក្រុមពិភាក្សា**

- ឯកឧត្តម នីយ រឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាល
- លោក លី ស៊ីវណ្ណា អនុប្រធាននាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
- លោក កែវ ភក្តី អនុប្រធាននាយកដ្ឋានច្បាប់កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ

**អ្នកបកប្រែ** :

ឧត្តមសេនីយ៍ទោ តេង ឈុន

២. **ក្រុមពិភាក្សាទី២ : អំពីបញ្ហាសេដ្ឋកិច្ច**

១-ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ប្រធាន

២-ឯកឧត្តម ឃី តាំងលឹម រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៣- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៤-ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៥- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦-ឯកឧត្តម ប៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ សមាជិក

៧-ឯកឧត្តម ទិ និរិទ្ធ ប្រធានអាជ្ញាធរអគ្គិសនី កម្ពុជា សមាជិក

-**លេខាររបស់ក្រុមពិភាក្សា**

-ឯកឧត្តម ប៊ុន អ៊ុយ អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តម ហង់ ជួនណារ៉ុន អគ្គលេខាធិការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

-លោក ហែម សាឯម ប្រធាននាយកដ្ឋានអាស៊ី១ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**អ្នកសម្របសម្រួល :**

-លោក ខាំ ពូន កែវ មុន្នី

៣. **ក្រុមពិភាក្សាទី៣ : អភិវឌ្ឍការអប់រំ វប្បធម៌ ទេសចរណ៍**

១-ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ប្រធាន

២-ឯកឧត្តម វេង សេរីវុឌ្ឍ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងទេសចរណ៍ សមាជិក

៣-សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៤-ឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រី ក្រសួងផែនការ សមាជិក

៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សុភា អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ សមាជិក

៦- ឯកឧត្តម ឧត្តមសេនីយ៍ឯក មល់ រឿប ទីប្រឹក្សាសម្តេច នាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការពារជាតិ សមាជិក

៧-ឯកឧត្តម វ៉ា គឹមហុង ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

៨-ឯកឧត្តម ស៊ិន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា សមាជិក

៩-ឯកឧត្តម យូ ស៊ុនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន សមាជិក

១០-លោកជំទាវ ស៊ុន សារឿន អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១១-ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ នាយរងសេនាធិការចំរុះ នាយកទីចាត់ការការងារព្រំដែន សមាជិក

១២-ឯកឧត្តម ស៊ឹម សួង ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារអាជ្ញាធរទេសចរណ៍ ជាតិកម្ពុជា សមាជិក

១៣-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

១៤- ឯកឧត្តម ព្រាប តាន់ អភិបាលខេត្ត ព្រះវិហារ សមាជិក

**+លេខារបស់ក្រុមពិភាក្សា**

-ឯកឧត្តម ស្វាយ ស៊ីថា អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី

-លោក សួស យ៉ារ៉ា អគ្គលេខាធិការអាជ្ញាធរទេសចរណ៍

-លោកស្រី កុយ ពិសី អនុប្រធាននាយកដ្ឋានព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី

4

**អ្នកបកប្រែ :**

-ឧត្តម សេនីយ៍ត្រី មៀច សុផាណា

**៤-ក្រុមពិភាក្សាទី៤ :អំពីបញ្ហាអភិវឌ្ឍន៍សង្គមកិច្ច និងសុខភាពសាធារណៈ**

១-ឯកឧត្តម ហុង ស៊ុនហួត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសុខាភិបាល ប្រធាន

២-ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

៣-លោកជំទាវ មូរ សុខហួរ រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក

៤-ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋលេខាធិការក្រសួង អប់រំ យុវជន និងកីឡា សមាជិក

**+លេខាធិការរបស់ក្រុមពិភាក្សា**

-ឯកឧត្តម សេង លឹមនៅ អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី

-លោក ថោង សុជាតិ ប្រធាននាយកដ្ឋាន

-លោក គឹម សុវណ្ណ ប្រធានការិយាល័យ នាយកដ្ឋានច្បាប់ កុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**អ្នកបកប្រែភាសារបស់ភាគីថៃ**

**៥-ក្រុមពិភាក្សាទី៥ :អំពីបញ្ហាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន**

១- ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រី ក្រសួង បរិស្ថាន ប្រធាន

២- ឯកឧត្តម សូ ឃុន រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

៣-ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សមាជិក

៤-ឯកឧត្តម លី ធុជ រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

៥- ឯកឧត្តម ច័ន្ទ តុងអ៊ីវ រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

**+លេខាធិការរបស់ក្រុមពិភាក្សា**

-ឯកឧត្តម ស៊ិន សារុន អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី

-លោក ជុំ សុន្ទរី ប្រធាននាយកដ្ឋានព័ត៌មាន ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ

-លោក កែវ វិចិត្រ អនុប្រធាននាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

**អ្នកបកប្រែភាសារបស់ភាគីថៃ**

**៦-ក្រុមបូកសរុប :**

| | |
|---|---|
| -ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| -ឯកឧត្តម ណាឌី តាន់ អគ្គលេខាធិការរាជរដ្ឋាភិបាល | សមាជិក |
| -ឯកឧត្តម ហូ សិទ្ធី នាយកខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| -ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| -ឯកឧត្តម ប្រាក់ សុខុន អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| -លោកជំទាវ ស៊ិន ស៊ីរី អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| -ឯកឧត្តម នឹម រឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| -ឯកឧត្តម ស្រ៊ី ថាមរុង្គ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| -ឯកឧត្តម ហួរ វិចិត្រ អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| -ឯកឧត្តម សយ សុខា អគ្គលេខាធិការ នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | លេខា |
| -លោក ចាប សុថារិទ្ធ ប្រធាននាយកដ្ឋានអាស៊ាន នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខា |
| -លោក ជា វ៉ាន់ដេត អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខា |

**អ្នកនាំពាក្យ**

-ឯកឧត្តម ប៉ែន ថុល ទីប្រឹក្សារបស់រាជរដ្ឋាភិបាល

-ឯកឧត្តម ខៀវ កាញ្ញារិទ្ធ រដ្ឋលេខាធិការ ក្រសួងព័ត៌មាន

-លោក ខៀវ ថារិកា ប្រធាននាយកដ្ឋានព័ត៌មាន និងសារគមនាគមន៍ នៃទីស្តីការគណៈរដ្ឋមន្ត្រី

**ប្រការ២ .-**

ក-ក្រុមពិភាក្សានីមួយៗ មានភារកិច្ចសិក្សា ពិចារណា លើឯកសារ ដែលស្នើឡើងដោយភាគីថៃ និងត្រៀមឯកសារ និងយោបល់បន្ថែមក្នុងករណីដែលយល់ឃើញថាចាំបាច់ត្រូវលើកជាមួយភាគីថៃ ។

-ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់ក្រុមនីមួយៗជូនសម្តេចនាយករដ្ឋមន្ត្រីតាមរយៈក្រុមបូកសរុប ។

-ធ្វើរបាយការណ៍ស្តីពីលទ្ធផលពិភាក្សា តាមក្រុមជាមួយភាគីថៃ សំរាប់រាយការណ៍ជូនអង្គប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី ចម្រុះ កម្ពុជា ថៃ ។

ខ-ក្រុមបូកសរុបមានភារកិច្ចដូចតទៅ :

-ធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលការងារ ដែលក្រុមពិភាក្សានីមួយៗ បានផ្តល់ឱ្យ ដើម្បីរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រី

-ធ្វើសេចក្តីប្រកាសព័ត៌មាន នៃការប្រជុំគណៈរដ្ឋមន្ត្រី ចម្រុះ កម្ពុជា ថៃ ។

-ធ្វើសេចក្តីជូនដំណឹងស្តីពីលទ្ធផល នៃការប្រជុំគណៈរដ្ឋមន្ត្រី ចម្រុះ កម្ពុជា ថៃ

-ត្រៀមខ្ទឹមសារសំរាប់ជូនសម្តេចនាយករដ្ឋមន្ត្រី

-កិច្ចការសរុបផ្សេងៗ

**ប្រការ៣ ៈ.**

សមាជិកក្រុមនីមួយៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្រុមពិភាក្សានីមួយៗមានសិទ្ធិ ប្រើប្រាស់ត្រារបស់ក្រសួង ស្ថាប័នសាមី ដើម្បីសំរួលការងារ ហើយត្រូវរំសាយជាស្វ័យប្រវត្តិ បន្ទាប់ពីចប់ភារកិច្ច ។

**ប្រការ៤ ៈ.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ឧសភា ឆ្នាំ ២០០៣

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ